**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**សាលាដំបូងខេត្តសៀមរាប**

**សាលក្រមព្រហ្មទណ្ឌ**

**លេខ ១៣(ឈ)/១៨៦**

ចុះថ្ងៃទី ៩ ខែ មីនា ឆ្នាំ ២០២៣

-សំណុំរឿងព្រហ្មទណ្ឌលេខ ៤៧៨

ចុះថ្ងៃទី ២១ ខែ មេសា ឆ្នាំ ២០២២

-សំណុំរឿងស៊ើបសួរលេខ ៤២៣

ចុះថ្ងៃទី ១៤ ខែ មិថុនា ឆ្នាំ ២០២២

-សំណុំរឿងជំនុំជម្រះលេខ ៦០

ចុះថ្ងៃទី ៣១ ខែ មករា ឆ្នាំ ២០២៣

## ក្នុងនាមប្រជារាស្ត្រខ្មែរ

## សាលាដំបូង ខេត្តសៀមរាប

កាលបរិច្ឆេទនៃសវនាការជាអសាធារណៈ ៖ ថ្ងៃទី ២២ ខែ កុម្ភៈ ឆ្នាំ ២០២៣

សាលសវនាការ និងពេលវេលា ៖ សាលលេខ ក៦ នៅម៉ោង ៨:៣០ព្រឹក

កាលបរិច្ឆេទនៃការប្រកាសសាលក្រម ៖ ថ្ងៃទី ៩ ខែ មីនា ឆ្នាំ ២០២៣

សាលសវនាការ និងពេលវេលា ៖ សាលលេខ ក២ នៅម៉ោង ៩:០០ព្រឹក

ក្រោមសមាសភាពជំនុំជម្រះ

**ក្រុមប្រឹក្សាជំនុំជម្រះ**

លោក [redacted] ជា ប្រធានក្រុមប្រឹក្សាជំនុំជម្រះ

លោកស្រី [redacted] ជា ចៅក្រមប្រឹក្សា

លោក [redacted] ជា ចៅក្រមប្រឹក្សា

**តំណាងអយ្យការ**

លោក [redacted] ព្រះរាជអាជ្ញារង អមសាលាដំបូង

**ក្រឡាបញ្ជីសវនាការ**

លោក [redacted] ក្រឡាបញ្ជី សាលាដំបូង

**ដើម្បីធ្វើការពិភាក្សាដេញដោលលើ**

សំណុំរឿងព្រហ្មទណ្ឌលេខ ៤៧៨ ចុះថ្ងៃទី២១ ខែមេសា ឆ្នាំ២០២២ ដែលមានជនជាប់ចោទ ៖

១/-ឈ្មោះ [redacted] **វាសនា** ភេទប្រុស អាយុ១៧ឆ្នាំ (កើតថ្ងៃទី២៩ ខែឧសភា ឆ្នាំ២០០៥) ជនជាតិខ្មែរ សញ្ជាតិខ្មែរ កាន់សាសនាព្រះពុទ្ធ ទីកន្លែងកំណើតនៅ [redacted] ខេត្តសៀមរាប មានទីលំនៅបច្ចុប្បន្ននៅភូមិ [redacted] ខេត្តសៀមរាប កម្រិតវប្បធម៌ មិនបានរៀន មុខរបរ ចុងភៅ នៅលីវ ឪពុកឈ្មោះ [redacted] រតនៈ (ស) ម្តាយឈ្មោះ [redacted] ស្រីនិច (ស) ទោសពីមុន មាន (ឃុំខ្លួនក្នុងពន្ធនាគារខេត្តសៀមរាប ក្នុងសំណុំរឿងព្រហ្មទណ្ឌលេខ ៤៥៨ ចុះថ្ងៃទី១៤ ខែមេសា ឆ្នាំ២០២២) (ក្នុងឃុំ) ។

*-ដីកាបង្គាប់ឱ្យឃុំខ្លួនលេខ ៧៦៣ ឃឧ/គ ចុះថ្ងៃទី១ ខែវិច្ឆិកា ឆ្នាំ២០២២ ។*

- លោក [redacted] ជាមេធាវីការពារសិទ្ធិ ។

២/-ឈ្មោះ [redacted] **ពិសិដ្ឋ** ភេទប្រុស អាយុ២៩ឆ្នាំ (កើតថ្ងៃទី២០ ខែកញ្ញា ឆ្នាំ១៩៩៣) ជនជាតិខ្មែរ សញ្ជាតិខ្មែរ កាន់សាសនាព្រះពុទ្ធ ទីកន្លែងកំណើតនៅ [redacted] រាជធានីភ្នំពេញ មានទីលំនៅបច្ចុប្បន្ននៅភូមិតាវៀន សង្កាត់សាលាកំរើក ក្រុងសៀមរាប ខេត្តសៀមរាប កម្រិតវប្បធម៌ ថ្នាក់ទី៣ មុខរបរជាងម៉ូតូ នៅលីវ ឪពុកឈ្មោះ [redacted] ជាតិ (ស) ម្តាយឈ្មោះ [redacted] ពៅ (ស) ទោសពីមុន មាន (ឃុំខ្លួនក្នុងពន្ធនាគារខេត្តសៀមរាប ក្នុងសំណុំរឿងព្រហ្មទណ្ឌលេខ ៤៥៨ ចុះថ្ងៃទី១៤ ខែមេសា ឆ្នាំ២០២២) (ក្នុងឃុំ) ។

*-ដីកាបង្គាប់ឱ្យឃុំខ្លួនលេខ ៧៦៤ យខ/គ ចុះថ្ងៃទី១ ខែវិច្ឆិកា ឆ្នាំ២០២២ ។*

៣/-ឈ្មោះ [redacted] **លីណា** ភេទស្រី អាយុ៣៥ឆ្នាំ (កើតថ្ងៃទី១១ ខែកញ្ញា ឆ្នាំ១៩៨៨) ជនជាតិខ្មែរ កាន់សាសនាព្រះពុទ្ធ ទីកន្លែងកំណើតនៅ[redacted] រាជធានីភ្នំពេញ មានទីលំនៅបច្ចុប្បន្ននៅភូមិតាវៀន សង្កាត់សាលាកំរើក ក្រុងសៀមរាប ខេត្តសៀមរាប កម្រិតវប្បធម៌ ថ្នាក់ទី៦ មុខរបរនៅផ្ទះ មេម៉ាយ មានកូនចំនួន២នាក់ ឪពុកឈ្មោះ [redacted] ជា (ស) ម្តាយឈ្មោះ [redacted] គឹមឡាង (រ) ទោសពីមុន មាន (ឃុំខ្លួនក្នុងពន្ធនាគារខេត្តសៀមរាប ក្នុងសំណុំរឿងព្រហ្មទណ្ឌលេខ ៤៥៨ ចុះថ្ងៃទី១៤ ខែមេសា ឆ្នាំ២០២២) (ក្នុងឃុំ) ។

*-ដីកាបង្គាប់ឱ្យឃុំខ្លួនលេខ ៧៦៥ យខ/គ ចុះថ្ងៃទី១ ខែវិច្ឆិកា ឆ្នាំ២០២២ ។*

ជនទាំងនេះត្រូវបានបញ្ជូនមកជំនុំជម្រះពីបទ **លួច** ប្រព្រឹត្តនៅចំណុចភូមិសាលាកន្សែង សង្កាត់ស្វាយដង្គំ ក្រុងសៀមរាប ខេត្តសៀមរាប កាលពីថ្ងៃទី១៣ ខែមេសា ឆ្នាំ២០២២ បទល្មើសព្រហ្មទណ្ឌដែលមានចែងឱ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ៣៥៣ និងមាត្រា ៣៥៦ នៃក្រមព្រហ្មទណ្ឌ ។

## ដើមបណ្តឹងរដ្ឋប្បវេណី

-ឈ្មោះ [redacted] **ឡិក** ភេទប្រុស អាយុ២៧ឆ្នាំ ជនជាតិខ្មែរ សញ្ជាតិខ្មែរ មុខរបរ រត់ម៉ូតូឌុប ទីលំនៅបច្ចុប្បន្ននៅភូមិវាល សង្កាត់គោកចក ក្រុងសៀមរាប ខេត្តសៀមរាប ។

## អង្គហេតុដែលប្តឹងមកតុលាការ

កាលពីថ្ងៃទី១២ ខែមេសា ឆ្នាំ២០២២ វេលាម៉ោង២៣ និង០០នាទី ឈ្មោះ [redacted] ឡិក ភេទប្រុស អាយុ២៧ឆ្នាំ បានទុកម៉ូតូម៉ាកហុងដាឌ្រីម សេ១២៥ ពណ៌ខ្មៅ ស៊េរី២០២០ លេខតួ និងលេខម៉ាស៊ីន ៥៧៨១៩២៦ ពាក់ផ្លាកលេខ សៀមរាប 1AJ-1825 នៅមុខបន្ទប់ជួល ដោយបានចាក់សោកត្រឹមត្រូវ ។ លុះដល់ម៉ោង៥ និង៥៣នាទីទៀបភ្លឺថ្ងៃទី១៣ ខែមេសា ឆ្នាំ២០២២ ទើបជនរងគ្រោះដឹងថាបាត់ម៉ូតូ ហើយបានទៅដាក់ពាក្យបណ្តឹងតែម្តង ។ ក្រោយពីទទួលបានពាក្យបណ្តឹងរួចមក នៅថ្ងៃទី១៣ ខែមេសា ឆ្នាំ២០២២ វេលាម៉ោង១៦ និង០០នាទី សមត្ថកិច្ចបានស្រាវជ្រាវរហូតឃាត់ខ្លួនបានជនជាប់ចោទ ៣នាក់ គឺឈ្មោះ[redacted] វាសនា ភេទប្រុស អាយុ១៧ឆ្នាំ ឈ្មោះ [redacted] ពិសិដ្ឋ ភេទប្រុស អាយុ២៩ឆ្នាំ និងឈ្មោះ សុខ លីណា ភេទស្រី អាយុ៣៥ឆ្នាំ ។ ពេលឃាត់ខ្លួនជនជាប់ចោទឈ្មោះ [redacted] វាសនា និងឈ្មោះ [redacted] ពិសិដ្ឋ បានសារភាពថា ពួកគេពិតជាបានលួចម៉ូតូរបស់ជនរងគ្រោះប្រាកដមែន ហើយពេលលួចម៉ូតូបាន គឺពួកគេយកទៅទុកនៅផ្ទះរបស់ជនជាប់ចោទឈ្មោះ [redacted] លីណា ស្ថិតនៅភូមិតាវៀន សង្កាត់សាលាកំរើក ក្រុងសៀមរាប ខេត្តសៀមរាប ។

- **បានឃើញ** ពាក្យបណ្តឹង ចុះថ្ងៃទី១៣ ខែមេសា ឆ្នាំ២០២២ របស់ឈ្មោះ [redacted] ឡិក ។
- **បានឃើញ** ដីកាសន្និដ្ឋានស្ថាពរលេខ ៨៤៨ អយយ/២២ ចុះថ្ងៃទី១៥ ខែធ្នូ ឆ្នាំ២០២២ របស់តំណាងអយ្យការអមសាលាដំបូងខេត្តសៀមរាប ។
- **បានឃើញ** ដីកាសម្រេចបញ្ជូនសំណុំរឿងទៅជំនុំជម្រះលេខ ៥៣២៧ ពស.ព្រស/គ ចុះថ្ងៃទី១៥ ខែធ្នូ ឆ្នាំ២០២២ របស់ចៅក្រមស៊ើបសួរសាលាដំបូងខេត្តសៀមរាប ។
- **បានឃើញ** ដីកាចាត់តាំងក្រុមប្រឹក្សាក្រុមចៅជំនុំជម្រះលេខ ៦៨ ពស.ព្រជ(ក) ចុះថ្ងៃទី៣១ ខែមករា ឆ្នាំ២០២៣ របស់ប្រធានសាលាដំបូងខេត្តសៀមរាប ។



Scanned with CamScanner

## អំពីកិច្ចពិភាក្សាដេញដោលនាពេលសវនាការ

-ជនជាប់ចោទឈ្មោះ [redacted] លីណា បានឆ្លើយថា ខ្លួនមិនបានដឹងរឿងអ្វីពាក់ព័ន្ធនឹងការលួចម៉ូតូនោះទេ ។ ម៉ូតូដែលសមត្ថកិច្ចដែលដកហូតចំនួន៣គ្រឿង ខ្លួនមិនដឹងថាជារបស់អ្នកណា និងលួចពីពេលណាដែរ ។ ខ្លួន និងឈ្មោះ[redacted]ពិសិដ្ឋ គឺជាសង្សានឹងគ្នា និងបានរួមរស់ជាមួយគ្នាបានប្រហែលជិត២ខែ ខ្លួនស្គាល់គ្នាតាមរយៈហ្វេសបុក(Facebook) ។ ឈ្មោះ [redacted] ពិសិដ្ឋ ប្រាប់ខ្លួនថា គេជាជាងឡានជាងម៉ូតូ ។ កាលពីយប់ថ្ងៃទី១២ ខែមេសា ឆ្នាំ២០២២ ខ្លួនបានផឹកស៊ីជាមួយឈ្មោះ [redacted] ពិសិដ្ឋ យប់នោះខ្លួនមិនបានដេកបន្ទប់ជាមួយឈ្មោះ[redacted] ពិសិដ្ឋ ទេ គឺដេកក្នុងបន្ទប់ជាមួយកូនស្រីខ្លួនដែលមានអាយុ៥ឆ្នាំ ។ ខ្លួនមិនសូវបាននៅបន្ទប់ជាប់លាប់នោះទេ គឺមកតែមួយភ្លែតៗប៉ុណ្ណោះ ព្រោះខ្លួននៅបន្ទប់ជាមួយបងស្រីខ្លួនផ្សេងទៀត ។ លុះថ្ងៃទី១៣ ខែមេសា ឆ្នាំ២០២៦ ខ្លួនបានមកបន្ទប់ជួលដែលនៅជាមួយឈ្មោះ[redacted]ពិសិដ្ឋ ក៏បានឃើញម៉ូតូម៉ាកឃ្លិកពណ៌សនៅក្នុងបន្ទប់ ពេលនោះខ្លួនសួរឈ្មោះ[redacted] ពិសិដ្ឋ ថាម៉ូតូអ្នកណាគេ ហើយឈ្មោះ [redacted] ពិសិដ្ឋ ក៏ប្រាប់ថាម៉ូតូមិត្តភក្តិរបស់គាត់យកមកផ្ញើល្ងាចម្ចាស់គេមកយកទៅវិញហើយ ខ្លួនក៏មិនបានសួរដេញដោលអ្វីទៀតដែរ ។ បានបន្តិចក្រោយមក ស្រាប់តែសមត្ថកិច្ចមកចាប់ខ្លួនឈ្មោះ[redacted]ពិសិដ្ឋ និងបានហៅខ្លួនដែលជាម្ចាស់បន្ទប់ទៅបំភ្លឺហើយក៏ឃាត់ខ្លួនរូបខ្លួន ជាមួយឈ្មោះ [redacted] ពិសិដ្ឋ តែម្តង ។ ខ្លួនមិនដែលស្គាល់ឈ្មោះ [redacted] វាសនា និងឈ្មោះ ចេក នោះទេ ។ ខ្លួនមិនដឹងថាឈ្មោះ[redacted] ពិសិដ្ឋ បានធ្វើសកម្មភាពលួចម៉ូតូគេ ឬអត់នោះទេ ។ កងម៉ូតូជារបស់ឈ្មោះ[redacted] ពិសិដ្ឋ ។ ផ្លាកលេខម៉ូតូខ្លួនអត់ដឹងនោះទេ ប៉ូលិសរកឃើញ ។ នៅពេលគេយកម៉ូតូមកដាក់ខ្លួនអត់ដឹងនោះទេ ។ បន្ទប់នោះខ្លួននៅជាន់លើ ហើយម៉ូតូនៅជាន់ក្រោម របស់របរដែលប៉ូលិសបានរឹបអូសនោះខ្លួនមិនដឹងនោះទេ ។ ខ្លួនសុំរក្សាចម្លើយដែលសួរឆ្លើយនៅតុលាការដដែល ។

- ជនជាប់ចោទឈ្មោះ [redacted] វាសនា បានឆ្លើយថា កាលពីថ្ងៃទី១៣ ខែមេសា ឆ្នាំ២០២២ វេលាម៉ោងប្រហែលពីរ ឬបី ទៀបភ្លឺ ពេលខ្លួនកំពុងដេកនៅក្នុងបន្ទប់ជួលរបស់ឈ្មោះ តឿ ម្នាក់ឯង ស្រាប់ឈ្មោះ ចេក បានយកម៉ូតូមួយគ្រឿងម៉ាកឌ្រីម ពណ៌ខ្មៅ ស៊េរីឆ្នាំ២០២០ មិនដឹងផ្លាកលេខប៉ុន្មានទេមកផ្ញើនៅបន្ទប់ជួលរបស់ឈ្មោះ តឿ ដែលមានទីតាំងស្ថិតនៅក្រោយសាលារៀនបឋមសិក្សាឆ្លកអណ្តូងដោយពេលនោះឈ្មោះ តឿ មិនបាននៅបន្ទប់នោះទេ គឺនៅតែខ្លួនម្នាក់ឯងប៉ុណ្ណោះ ហើយឈ្មោះ ចេក ប្រាប់ថាម៉ូតូនោះជា ម៉ូតូរបស់សង្សាគាត់ ។ ពេលឈ្មោះ ចេក យកម៉ូតូមកផ្ញើរួចហើយ ក៏ចេញទៅវិញ បានមួយសន្ទុះឈ្មោះ ចេក ក៏មកយកម៉ូតូដែលផ្ញើនោះទៅវិញ លុះដល់វេលាម៉ោងប្រហែលបួនទៀបភ្លឺ ក៏បានយកម៉ូតូមកផ្ញើម្តងទៀត ម៉ូតូដែលផ្ញើក្រោយនេះម៉ាកឌ្រីម ពណ៌ខ្មៅ ស៊េរីឆ្នាំ២០២០ ដូចមុនដែរ ប៉ុន្តែមិនដឹងថាជាម៉ូតូដដែល ឬម៉ូតូផ្សេងនោះទេ ។ នៅថ្ងៃទី១២ ខែមេសា ឆ្នាំ២០២២ វេលាម៉ោងប្រហែលដប់យប់ ឈ្មោះ [redacted]ពិសិដ្ឋ បានមកសុំខ្ចីម៉ូតូរបស់ខ្លួនយកទៅជិះមួយភ្លែត ដោយគាត់ប្រាប់ថាយកទៅឱបមិត្តភក្តិរបស់គាត់ដើរលេង ហើយខ្លួនក៏បានឱ្យម៉ូតូទៅឈ្មោះ [redacted] ពិសិដ្ឋ តែម្តង ។ លុះដល់ម៉ោងប្រហែល បួន ឬម៉ោងប្រាំព្រឹក ឈ្មោះ[redacted]ពិសិដ្ឋ ក៏បានយកម៉ូតូមកឱ្យខ្លួនវិញ រហូតដល់ម៉ោងប្រហែល បី ឬម៉ោងបួនល្ងាច ស្រាប់តែឈ្មោះ [redacted] ពិសិដ្ឋ នាំសមត្ថកិច្ចមកចាប់ខ្លួនរូបខ្លួនតែម្តង ។ ចំពោះឈ្មោះ [redacted] លីណា ខ្លួនមិនដែលស្គាល់គាត់នោះទេ តែធ្លាប់ទៅផឹកស្រានៅផ្ទះរបស់គាត់ ។ ខ្លួនទើបតែមកពីភ្នំពេញមកសុំបន្ទប់របស់ តឿ ស្នាក់នៅបានប្រហែល បី ឬបួន ថ្ងៃប៉ុណ្ណោះ មុនសមត្ថកិច្ចចាប់ខ្លួន ។ ខ្លួនឈឺដេកនៅពេទ្យខេត្តសៀមរាប ។ ពាក់ព័ន្ធនឹងឈ្មោះ [redacted] ពិសិដ្ឋ លួចម៉ូតូខ្លួនមិនដឹងនោះទេ ។ ចម្លើយពីមុនខ្លួនសុំរក្សាដដែល ។

-ជនជាប់ចោទឈ្មោះ[redacted]ពិសិដ្ឋ បានឆ្លើយថា ម៉ូតូនេះ គឺឈ្មោះ ចេក បានយកទៅផ្ញើនៅបន្ទប់ជួលរបស់ឈ្មោះ[redacted]វាសនា និង តឿ ស្ថិតនៅជិតវត្តត្រាំនាគ ចំណែកបន្ទប់ជួលរបស់ខ្លួនស្ថិតនៅក្រោយផ្សារ

លើ ដោយខ្លួននៅបន្ទប់ជួលជាមួយឈ្មោះ [redacted] លីណា ភេទស្រី ។ ខ្លួនមិនដឹងថាឈ្មោះ ចេក បានយកម៉ូតូខាងលើនេះទៅផ្ញើនឹងឈ្មោះ [redacted] វ៉ាសនា នៅថ្ងៃណានោះទេ ហើយខ្លួនក៏មិនដឹងថាឈ្មោះ ចេក បានម៉ូតូនេះមកពីណាដែរ ។ នៅថ្ងៃទី១២ ខែមេសា ឆ្នាំ២០២២ វេលាម៉ោងប្រហែល៤ ឬ៥ ព្រឹក ឈ្មោះ ចេក បានយកម៉ូតូមួយគ្រឿងម៉ាកហុងដាឌ្រីម ពណ៌ក្រហម ស៊េរីឆ្នាំ២០១៩ ឡើងតែមឆ្នាំ២០២២ មិនចាំផ្លាកលេខមកផ្ញើនៅបន្ទប់ជួលរបស់ខ្លួន និងឈ្មោះ [redacted] លីណា ពេលនោះខ្លួនសួរថាម៉ូតូអ្នកណា ហើយឈ្មោះ ចេក ប្រាប់ថាម៉ូតូនេះ គឺជាម៉ូតូបងប្អូនរបស់គាត់ លុះដល់ម៉ោងប្រហែល ៨ ឬ៩ព្រឹក ឈ្មោះ ចេក ក៏បានយកម៉ូតូមួយគ្រឿងទៀត មកឱ្យខ្លួន ម៉ាកហុងដាឌ្រីម ពណ៌ខ្មៅ ស៊េរីឆ្នាំ២០២០ មិនចាំផ្លាកលេខ មកលក់ឱ្យខ្លួនតែមិនទាន់និយាយតម្លៃគ្នាទេ ដោយគាត់ប្រាប់ថា យកជិះសិនទៅ ចាំពេលមានលុយ ចាំនិយាយតម្លៃជាមួយគាត់ ពេលនោះខ្លួនក៏ទទួលយកម៉ូតូនោះមកទុកជិះតែម្តង ។ លុះថ្ងៃទី១៣ ខែមេសា ឆ្នាំ២០២២ ស្រាប់តែសមត្ថកិច្ចមកចាប់រូបខ្លួន និងឈ្មោះ [redacted] លីណា នៅក្នុងបន្ទប់ជួលតែម្តង ដោយបានដកហូតម៉ូតូចំនួន ៣ (បី)គ្រឿង មានម៉ូតូរបស់បងខ្លួនឈ្មោះ ផាន (បច្ចុប្បន្នស្លាប់បាត់ហើយ) ចំនួន១ (មួយ)គ្រឿង និងម៉ូតូដែលឈ្មោះ ចេក យកមកផ្ញើចំនួន ២(ពីរ) គ្រឿង ។ បន្ទាប់មកសមត្ថកិច្ចឱ្យខ្លួនទៅចាប់ឈ្មោះ ចេក ប៉ុន្តែពេលខ្លួននាំទៅឱ្យឈ្មោះ ចេក បានរត់គេចខ្លួនបាត់ ហើយសមត្ថកិច្ចសួរខ្លួនថាស្គាល់ឈ្មោះ ចេក តាមណាខ្លួនប្រាប់ថាស្គាល់តាមរយៈឈ្មោះ [redacted] វ៉ាសនា ពេលនោះសមត្ថកិច្ចក៏ឱ្យខ្លួននាំទៅបន្ទប់របស់ឈ្មោះ [redacted] វ៉ាសនា ទៀត ពេលខ្លួននាំទៅដល់សមត្ថកិច្ចក៏ចាប់ខ្លួនឈ្មោះ [redacted] វ៉ាសនា មកជាមួយដែរ ។ កន្លងមកឈ្មោះ ចេក ភេទប្រុស អាយុប្រហែល ៣៦ឆ្នាំ មិនដែលយកម៉ូតូមកផ្ញើនៅបន្ទប់ជួលខ្លួននោះទេ ទើបតែយកមកផ្ញើនៅថ្ងៃទី១២ ខែមេសា ឆ្នាំ២០២២ ចំនួន២គ្រឿង ក៏ត្រូវសមត្ថកិច្ចចាប់ខ្លួនរូបខ្លួនតែម្តង ។ កាលពីថ្ងៃទី១២ ខែមេសា ឆ្នាំ២០២២ ឈ្មោះ ចេក បានមកពឹងខ្លួនឱ្យទៅខ្ចីម៉ូតូរបស់ឈ្មោះ [redacted] វ៉ាសនា មកឱ្យគាត់ជិះ ខ្លួនក៏សួរថាម៉េចមិនទៅខ្ចីខ្លួនឯង គាត់ប្រាប់គាត់ខ្ចីមិនបានទេ ។ បន្ទាប់ពីខ្លួនខ្ចីម៉ូតូឈ្មោះ [redacted] វ៉ាសនា បានហើយខ្លួនក៏ឱ្យទៅឈ្មោះ ចេក យកទៅជិះតែម្តង ។ បន្ទាប់ពីជិះរួចហើយឈ្មោះ ចេក ក៏បានយកម៉ូតូមកឱ្យខ្លួនវិញ ហើយខ្លួនក៏យកទៅប្រគល់ឱ្យឈ្មោះ [redacted] វ៉ាសនា វិញតែម្តង បន្តិចក្រោយមកស្រាប់តែឈ្មោះ ចេក បានយកម៉ូតូមកផ្ញើនឹងខ្លួនតែម្តង ដោយប្រាប់ថាជាម៉ូតូបងប្អូនរបស់គាត់ ។ ខ្លួនមិនមានម៉ូតូដែលជាកម្មសិទ្ធិខ្លួនឯងនោះទេ ។ ចំពោះឈ្មោះ [redacted] លីណា គាត់មិនបានដឹងរឿងអ្វីទេ ដោយនៅថ្ងៃដែលឈ្មោះ ចេក យកម៉ូតូមកផ្ញើទុកនៅក្នុងបន្ទប់ខ្លួន និងគាត់នោះ គឺគាត់មិនបាននៅបន្ទប់នោះ ដោយគាត់ទៅនៅមើលថែបងរបស់គាត់ឈ្មោះ ផាន់ ដែលសម្រាកព្យាបាលនៅមន្ទីរពេទ្យ លុះដល់ថ្ងៃទី១៣ ខែមេសា ឆ្នាំ២០២២ គាត់ក៏បានត្រឡប់មកវិញ ហើយគាត់សួរខ្លួនថាម៉ូតូអ្នកណាទុកនៅក្នុងបន្ទប់ ខ្លួនក៏ប្រាប់គាត់ថាម៉ូតូគេយកមកផ្ញើពេលល្ងាចម្ចាស់គេមកយកទៅវិញហើយ លុះបានប្រហែលមួយម៉ោងក៏ត្រូវសមត្ថកិច្ចមកចាប់ខ្លួនរូបខ្លួន និងចាប់ទាំងឈ្មោះ [redacted] លីណា តែម្តង ។ ខ្លួនមិនដឹងថាឈ្មោះ [redacted] វ៉ាសនា បានធ្វើសកម្មភាពលួចម៉ូតូម៉ាកហុងដាឌ្រីម សេ១២៥ ស៊េរីឆ្នាំ២០២០ ពាក់ផ្លាកលេខ សៀមរាប 1AJ-1825 ជាមួយឈ្មោះ ចេក ឬអត់នោះទេ ។ ម៉ូតូម៉ាកឃ្លិកមានគ្រឿងម៉ូតូរបស់ឈ្មោះ ចេក ។ សំបកកងម៉ូតូជារបស់ខ្លួន ហើយរឿងកាប់និងផ្លាកលេខរបស់ឈ្មោះ ចេក មិនមែនរបស់ខ្លួននោះទេ ។ រឿងលួចម៉ូតូខ្លួនមិនដឹងនោះទេ ហើយឈ្នួលផ្ញើម៉ូតូក៏មិនបានយកដែរ ។

-តាមអំណានចម្លើយរបស់ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] ឡឹក បានឆ្លើយនៅដំណាក់កាលមន្ត្រីនគរបាលយុត្តិធម៌ថា កាលពីថ្ងៃទី១២ ខែមេសា ឆ្នាំ២០២២ វេលាម៉ោង ២៣ និង០០នាទី ខ្លួនបានជិះម៉ូតូរបស់ខ្លួន ម៉ាកហុងដាឌ្រីម ស៊េរីឆ្នាំ២០២០ ពាក់ផ្លាកលេខ 1AJ-1825 ទៅផឹកស៊ីនៅផ្ទះបងប្អូន

ជីដូនមួយឈ្មោះ ផិន នៅភូមិសាលាកន្សែង សង្កាត់ស្វាយដង្គំ ក្រុងសៀមរាប ខេត្តសៀមរាប ។ ពេលទៅដល់ខ្លួនបានទុកម៉ូតូនៅខាងក្រោមបរិវេណបន្ទប់ជួលមិនបានចាក់សោកទេ រួចនាំគ្នាផឹកស៊ី ក្នុងផ្ទះដល់ថ្ងៃទី១៣ ខែមេសា ឆ្នាំ២០២២ ម៉ោង ៥ និង០០នាទីព្រឹក ខ្លួនចេញមកមើលម៉ូតូឃើញនៅធម្មតា លុះដល់ ម៉ោង ៦ និង០០នាទី ខ្លួនចេញមករកម៉ូតូជិះទៅផ្ទះស្រាប់តែបាត់ម៉ូតូ ពេលឆែកកាមេរ៉ាសុវត្ថិភាពក៏ឃើញមានមនុស្សម្នាក់ស្លៀកខោជើងវែង ពណ៌ខ្មៅ ពាក់ស្បែកជើងក្រឡាការ៉ូជាអ្នកចូលមកលួចយកម៉ូតូរបស់ខ្លួន ។ បន្ទាប់មកខ្លួនក៏ដាក់ពាក្យបណ្តឹងតែម្តង ។

## សេចក្តីសន្និដ្ឋានរបស់តំណាងអយ្យការ

ក្រោយពីធ្វើការពិភាក្សា សួរដេញដោល តាមការស្តាប់ចម្លើយរបស់ជនជាប់ចោទទាំងបីនាក់រួចមក តំណាងអយ្យការយល់ឃើញថា ពិតជាមានអង្គហេតុនៃការចោទប្រកាន់ប្រាកដមែន ដូច្នេះតំណាងអយ្យការស្នើសុំតុលាការផ្តន្ទាទោសជនជាប់ចោទតាមច្បាប់ ។

## សេចក្តីសន្និដ្ឋានរបស់មេធាវីការពារសិទ្ធិឱ្យជនជាប់ចោទ

ក្រោយពីធ្វើការពិភាក្សា សួរដេញដោលរួចមក ឃើញថា ទី១. នៅដំណាក់កាលមន្ត្រីនគរបាលយុត្តិធម៌ កូនក្តីខ្លួនឆ្លើយសារភាព ដោយសារសមត្ថកិច្ចមានវាយបង្ខំឱ្យកូនក្តីខ្លួនឆ្លើយសារភាព ។ ទី២. នៅដំណាក់កាលចៅក្រមស៊ើបសួរ កូនក្តីខ្លួនបានឆ្លើយបដិសេធថា ខ្លួនមិនបានប្រព្រឹត្តដូចការចោទប្រកាន់របស់ដំណាក់កាលមន្ត្រីនគរបាលយុត្តិធម៌ឡើយ ។ ទី៣. នៅដំណាក់កាលចៅក្រមជំនុំជម្រះនេះ សរុបរឿងខ្លួនយល់ឃើញថា ក្នុងរឿងនេះជនជាប់ចោទឈ្មោះ [redacted] វាសនា ពុំមានភស្តុតាងដាក់បន្ទុកគ្រប់គ្រាន់ថាកាលពីថ្ងៃទី១២ និងទី១៣ ខែមេសា ឆ្នាំ២០២២ កូនក្តីខ្លួនឈ្មោះ [redacted] វាសនា មិនបានចូលរួមលួចម៉ូតូនោះទេ ។ ដូច្នេះខ្លួនស្នើសុំតុលាការឱ្យកូនក្តីខ្លួនឈ្មោះ [redacted] វាសនា រួចផុតពីបទចោទ ។

## សំដីចុងក្រោយរបស់ជនជាប់ចោទ

ជនជាប់ចោទឈ្មោះ [redacted] ពិសិដ្ឋ សំណូមពរសុំឱ្យតុលាការបន្ធូរបន្ថយទោសឱ្យខ្លួនផង និងសុំឱ្យតុលាការលើកលែងការចោទប្រកាន់លើឈ្មោះ [redacted] លីណា ផង គាត់មិនមានការពាក់ព័ន្ធអ្វីឡើយ ។

ជនជាប់ចោទឈ្មោះ [redacted] វាសនា សំណូមពរសុំឱ្យតុលាការលើកលែងការចោទប្រកាន់ ព្រោះខ្លួនមិនបានពាក់ព័ន្ធក្នុងរឿងនេះទេ ខ្លួនគ្រាន់តែទទួលបញ្ញើម៉ូតូតែប៉ុណ្ណោះ ។

ជនជាប់ចោទឈ្មោះ [redacted] លីណា សំណូមពរសុំឱ្យតុលាការរកយុត្តិធម៌ឱ្យខ្លួនផង ។

-ក្រោយពីបានស្តាប់ចម្លើយរបស់ជនជាប់ចោទ

-ក្រោយពីបានស្តាប់អំណានចម្លើយរបស់ដើមបណ្តឹងរដ្ឋប្បវេណី

-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋាន និងការប្តឹងសុំរបស់តំណាងអយ្យការ

-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់មេធាវីការពារសិទ្ធិឱ្យជនជាប់ចោទ

-ក្រោយពីបានស្តាប់សំដីចុងក្រោយរបស់ជនជាប់ចោទ

-ក្រោយពីបានពិនិត្យលើឯកសារ ភស្តុតាងនានា

-ក្រោយពីបានពិចារណាត្រឹមត្រូវតាមច្បាប់ហើយ

## សំអាងហេតុ

១/- សាលាដំបូងខេត្តសៀមរាប បានទទួលសំណុំរឿងព្រហ្មទណ្ឌលេខ ៤៧៨ ចុះថ្ងៃទី២១ ខែមេសា ឆ្នាំ២០២២ ដែលមានជនជាប់ចោទឈ្មោះ [redacted] វាសនា ភេទប្រុស អាយុ១៧ឆ្នាំ (កើតថ្ងៃទី២៩ ខែឧសភា ឆ្នាំ២០០៥) ឈ្មោះ [redacted] ពិសិដ្ឋ ភេទប្រុស អាយុ២៩ឆ្នាំ (កើតថ្ងៃទី២០ ខែកញ្ញា ឆ្នាំ១៩៩៣) និង

ឈ្មោះ [redacted] លីណា ភេទស្រី អាយុ៣៥ឆ្នាំ (កើតថ្ងៃទី១១ ខែកញ្ញា ឆ្នាំ១៩៨៨) ដែលត្រូវបានបញ្ជូនមកជំនុំជម្រះពីបទ លួច ប្រព្រឹត្តនៅចំណុចភូមិសាលាកន្សែង សង្កាត់ស្វាយដង្គំ ក្រុងសៀមរាប ខេត្តសៀមរាប កាលពីថ្ងៃទី១៣ ខែមេសា ឆ្នាំ២០២២ បទល្មើសព្រហ្មទណ្ឌដែលមានចែងឱ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា៣៥៣ និងមាត្រា ៣៥៦ នៃក្រមព្រហ្មទណ្ឌ តាមដីកាសម្រេចបញ្ជូនសំណុំរឿងទៅជំនុំជម្រះលេខ ៥៣២៧ ៣ស.ព្រស/គ ចុះថ្ងៃទី១៥ ខែធ្នូ ឆ្នាំ២០២២ របស់ចៅក្រមស៊ើបសួរនៃសាលាដំបូងខេត្តសៀមរាប និងតាមមាត្រា ២៩១ នៃក្រមនីតិវិធីព្រហ្មទណ្ឌ នាំឱ្យសាលាដំបូងខេត្តសៀមរាប មានសមត្ថកិច្ចក្នុងការជំនុំជម្រះ ។

២/- តាមដីកាបញ្ជូនសំណុំរឿងទៅជំនុំជម្រះលេខ ៥៣២៧ ៣ស.ព្រស/គ ចុះថ្ងៃទី១៥ ខែធ្នូ ឆ្នាំ ២០២២ របស់ចៅក្រមស៊ើបសួរនៃសាលាដំបូងខេត្តសៀមរាប ដែនកំណត់នៃការប្តឹងមកតុលាការចំពោះអង្គហេតុ តាមមាត្រា ៣៤៨ នៃក្រមនីតិវិធីព្រហ្មទណ្ឌ និងដែនកំណត់នៃការប្តឹងមកតុលាការចំពោះបុគ្គល តាមមាត្រា ៣៤៩ នៃក្រមនីតិវិធីព្រហ្មទណ្ឌ នាំឱ្យសាលាដំបូងខេត្តសៀមរាបមានសមត្ថកិច្ចក្នុងការជំនុំជម្រះលើអង្គហេតុដែលប្តឹងមកតុលាការ និងចំពោះជនជាប់ចោទឈ្មោះ [redacted] វាសនា ឈ្មោះ [redacted] ពិសិដ្ឋ និងឈ្មោះ [redacted] លីណា ។

៣/- ជនជាប់ចោទឈ្មោះ [redacted] វាសនា បានឆ្លើយនៅដំណាក់កាលចៅក្រមស៊ើបសួរ និងនាពេលសវនាការថា ខ្លួនមិនបានប្រព្រឹត្តដូចការចោទប្រកាន់ និងបញ្ជូនមកជំនុំជម្រះពាក់ព័ន្ធនឹងបទលួចនេះទេ ខ្លួនមិនដឹងនោះទេ ខ្លួនគ្រាន់តែជាអ្នកទទួលបញ្ញើម៉ូតូពីឈ្មោះ ចេក ហើយថាជាម៉ូតូរបស់សង្សារគាត់ ។ *ឃើញថា* ចម្លើយបដិសេធនូវបទចោទប្រកាន់ខាងលើ តាមរយៈអង្គហេតុកើតឡើងនៅចំណុចភូមិសាលាកន្សែង សង្កាត់ស្វាយដង្គំ ក្រុងសៀមរាប ខេត្តសៀមរាប កាលពីថ្ងៃទី១៣ ខែមេសា ឆ្នាំ២០២២ ពុំមានភាពស៊ីសង្វាក់គ្នាជាមួយចម្លើយដែលឈ្មោះ [redacted] វាសនា បានឆ្លើយនៅដំណាក់កាលមន្ត្រីនគរបាលយុត្តិធម៌ ភស្តុតាង និងរបាយការណ៍សំយោគ ដែលកសាងឡើងដោយមន្ត្រីនគរបាលយុត្តិធម៌នោះទេ ។ ហេតុនេះ តុលាការពិនិត្យឃើញថា ក្នុងសំណុំរឿងមានភស្តុតាងគ្រប់គ្រាន់ ដែលអាចបង្ហាញឱ្យតុលាការជឿបានថា អំពើរបស់ជនជាប់ចោទឈ្មោះ [redacted] វាសនា បំពេញគ្រប់ធាតុផ្សំនៃបទល្មើស លួច ប្រព្រឹត្តនៅចំណុចភូមិសាលាកន្សែង សង្កាត់ស្វាយដង្គំ ក្រុងសៀមរាប ខេត្តសៀមរាប កាលពីថ្ងៃទី១៣ ខែមេសា ឆ្នាំ២០២២ បទល្មើសព្រហ្មទណ្ឌដែលមានចែងតាមបញ្ញត្តិមាត្រា ៣៥៣ និងមាត្រា ៣៥៦ នៃក្រមព្រហ្មទណ្ឌ ។

៤/- ជនជាប់ចោទឈ្មោះ [redacted] ពិសិដ្ឋ បានឆ្លើយនៅដំណាក់កាលចៅក្រមស៊ើបសួរ និងនាពេលសវនាការថា ខ្លួនមិនបានប្រព្រឹត្តដូចការចោទប្រកាន់ និងបញ្ជូនមកជំនុំជម្រះពាក់ព័ន្ធនឹងបទលួចនេះ ខ្លួនមិនដឹងនោះទេ ខ្លួនគ្រាន់តែជាអ្នកទទួលបញ្ញើម៉ូតូពីឈ្មោះ ចេក ប៉ុណ្ណោះ ហើយសមត្ថកិច្ចបានបង្ខំឱ្យខ្លួនឆ្លើយទទួលស្គាល់ថាខ្លួនជាអ្នកលួច ។ ខ្លួនមិនបានធ្វើសកម្មភាពលួចម៉ូតូ ម៉ាកហុងដាឌ្រីម សេ១២៥ ស៊េរីឆ្នាំ២០២០ ពាក់ផ្លាកលេខ សៀមរាប 1AJ-1825 នោះទេ ។ ម៉ូតូនេះ គឺឈ្មោះ ចេក បានយកទៅផ្ញើនៅបន្ទប់ជួលរបស់ឈ្មោះ [redacted] វាសនា និង តឿ ស្ថិតនៅជិតវត្តគ្រាំនាគ ចំណែកបន្ទប់ជួលរបស់ខ្លួនស្ថិតនៅក្រោយផ្សារលើ ដោយខ្លួននៅបន្ទប់ជួលជាមួយឈ្មោះ [redacted] លីណា ។ ខ្លួនមិនដឹងថាឈ្មោះ ចេក បានយកម៉ូតូខាងលើនេះទៅផ្ញើនឹងឈ្មោះ [redacted] វាសនា នៅថ្ងៃណានោះទេ ហើយខ្លួនក៏មិនដឹងថាឈ្មោះ ចេក បានម៉ូតូនេះមកពីណាដែរ ។ *ឃើញថា* ចម្លើយបដិសេធនូវបទចោទប្រកាន់ខាងលើ តាមរយៈអង្គហេតុកើតឡើងនៅចំណុចភូមិសាលាកន្សែង សង្កាត់ស្វាយដង្គំ ក្រុងសៀមរាប ខេត្តសៀមរាប កាលពីថ្ងៃទី១៣ ខែមេសា ឆ្នាំ ២០២២ ពុំមានភាពស៊ីសង្វាក់គ្នាជាមួយចម្លើយដែលឈ្មោះ [redacted] ពិសិដ្ឋ បានឆ្លើយនៅដំណាក់កាលមន្ត្រី



Scanned with CamScanner

នគរបាលយុត្តិធម៌ ភស្តុតាងដែលដកហូត និងរបាយការណ៍សំយោគដែលកសាងឡើងដោយមន្ត្រីនគរបាលយុត្តិធម៌នោះទេ ។ ហេតុនេះ តុលាការពិនិត្យឃើញថា ក្នុងសំណុំរឿងមានភស្តុតាងគ្រប់គ្រាន់ ដែលអាចបង្ហាញឱ្យតុលាការជឿបានថា អំពើរបស់ជនជាប់ចោទឈ្មោះ [redacted] ពិសិដ្ឋ បំពេញគ្រប់ធាតុផ្សំនៃបទល្មើសលួច ប្រព្រឹត្តនៅចំណុចភូមិសាលាកន្សែង សង្កាត់ស្វាយដង្គំ ក្រុងសៀមរាប ខេត្តសៀមរាប កាលពីថ្ងៃទី១៣ ខែមេសា ឆ្នាំ២០២២ បទល្មើសព្រហ្មទណ្ឌដែលមានចែងតាមបញ្ញត្តិមាត្រា ៣៥៣ និងមាត្រា ៣៥៦ នៃក្រមព្រហ្មទណ្ឌ ។

៥/- ជនជាប់ចោទឈ្មោះ [redacted] លីណា បានឆ្លើយនៅដំណាក់កាលចៅក្រមស៊ើបសួរ និងនាពេលសវនាការថា ខ្លួនមិនបានប្រព្រឹត្តដូចការចោទប្រកាន់ និងបញ្ជូនមកជំនុំជម្រះពាក់ព័ន្ធនឹងបទលួចនេះ ខ្លួនមិនដឹងថាជាម៉ូតូរបស់អ្នកណា និងលួចពីពេលណាដែរ ។ ឈ្មោះ [redacted] ពិសិដ្ឋ បានយកម៉ូតូមកផ្ញើនៅបន្ទប់របស់ខ្លួន ខ្លួនបានសួរឈ្មោះ [redacted] ពិសិដ្ឋ ថាម៉ូតូអ្នកណាគេ ហើយឈ្មោះ [redacted] ពិសិដ្ឋ ក៏ប្រាប់ថាម៉ូតូមិត្តភក្តិរបស់គាត់យកមកផ្ញើល្ងាចម្ចាស់គេមកយកទៅវិញហើយ ខ្លួនក៏មិនបានសួរដេញដោលអ្វីទៀតដែរ ។ *ឃើញថា* ចម្លើយបដិសេធនូវបទចោទប្រកាន់ខាងលើ តាមរយៈអង្គហេតុកើតឡើងនៅចំណុចភូមិសាលាកន្សែង សង្កាត់ស្វាយដង្គំ ក្រុងសៀមរាប ខេត្តសៀមរាប កាលពីថ្ងៃទី១៣ ខែមេសា ឆ្នាំ២០២២ ពុំមានភាពស៊ីសង្វាក់គ្នាជាមួយចម្លើយដែលឈ្មោះ [redacted] វាសនា និងឈ្មោះ [redacted] ពិសិដ្ឋ បានឆ្លើយនៅដំណាក់កាលមន្ត្រីនគរបាលយុត្តិធម៌ ភស្តុតាងដែលរឹបអូសបាន និងរបាយការណ៍សំយោគ ដែលកសាងឡើងដោយមន្ត្រីនគរបាលយុត្តិធម៌នោះទេ ។ ហេតុនេះ តុលាការពិនិត្យឃើញថា ក្នុងសំណុំរឿងមានភស្តុតាងគ្រប់គ្រាន់ ដែលអាចបង្ហាញឱ្យតុលាការជឿបានថា អំពើរបស់ជនជាប់ចោទឈ្មោះ [redacted] លីណា បំពេញគ្រប់ធាតុផ្សំនៃបទល្មើសលួច ប្រព្រឹត្តនៅចំណុចភូមិសាលាកន្សែង សង្កាត់ស្វាយដង្គំ ក្រុងសៀមរាប ខេត្តសៀមរាប កាលពីថ្ងៃទី១៣ ខែមេសា ឆ្នាំ២០២២ បទល្មើសព្រហ្មទណ្ឌដែលមានចែងតាមបញ្ញត្តិមាត្រា ៣៥៣ និងមាត្រា ៣៥៦ នៃក្រមព្រហ្មទណ្ឌ ។

៦/- ចម្លើយបដិសេធនូវអង្គហេតុដែលប្ដឹងចោទប្រកាន់ និងបញ្ជូនមកជំនុំជម្រះពីបទលួច នាពេលសវនាការរបស់ជនជាប់ចោទឈ្មោះ [redacted] វាសនា ឈ្មោះ [redacted] ពិសិដ្ឋ និងឈ្មោះ [redacted] លីណា ពុំមានសង្គតភាពជាមួយចម្លើយសារភាពដែលបានឆ្លើយនៅដំណាក់មន្ត្រីនគរបាលយុត្តិធម៌នោះទេ ដូចមាន កំណត់ហេតុស្រង់ចម្លើយ ចុះថ្ងៃទី១៣ ខែមេសា ឆ្នាំ២០២២ នោះទេ។ ត្រង់ចំណុចនេះ *ឃើញថា* ចម្លើយរបស់ជនជាប់ចោទនៅដំណាក់កាលមន្ត្រីនគរបាលយុត្តិធម៌ ដែលជនជាប់ចោទឈ្មោះ [redacted] វាសនា បានដឹកឈ្មោះ [redacted] ពិសិដ្ឋ ធ្វើសកម្មភាពកាច់សោកលួចម៉ូតូ ពេលធ្វើសកម្មភាពលួចកាច់សោកម៉ូតូបានហើយ ក៏បានជិះម៉ូតូនោះយកទៅទុកនៅផ្ទះជួលរបស់ឈ្មោះ [redacted] លីណា ហើយរបៀបកាច់សោកម៉ូតូ ដោយគេប្រើសោរាងអក្សរ T ពេលសូកចូលសោកម៉ូតូ ដើម្បីបំបាក់ និងបំបែក ឱ្យបានធាប់រហ័ស គឺឈ្មោះ ចេក ជាអ្នកបង្រៀនខ្លួនទេ ។ នេះបង្ហាញឱ្យឃើញថា ជនជាប់ចោទឈ្មោះ [redacted] វាសនា និងឈ្មោះ [redacted] ពិសិដ្ឋ ពិតជាមានទំនាក់ទំនងយ៉ាងជិតស្និត និងស្ទាត់ជំនាញក្នុងការធ្វើសកម្មភាពលួច ខណៈដែលឈ្មោះ [redacted] ពិសិដ្ឋ និងឈ្មោះ [redacted] វាសនា បែរជាឆ្លើយដាក់បន្ទុកទៅលើឈ្មោះ ចេក ដែលជាបក្ខពួករបស់ខ្លួន ដើម្បីដោះបន្ទុកឲ្យខ្លួនឯងរួចផុតពីការទទួលខុសត្រូវ និងការចោទប្រកាន់នូវអំពើល្មើសច្បាប់របស់ខ្លួន តែប៉ុណ្ណោះ ។

៧/- ចម្លើយរបស់ជនជាប់ចោទ និងភស្តុតាងក្នុងសំណុំរឿង មានភាពស៊ីសង្វាក់គ្នាគ្រប់គ្រាន់ ដែលបង្ហាញឱ្យឃើញថា ជនជាប់ចោទឈ្មោះ [redacted] វាសនា ជនជាប់ចោទឈ្មោះ [redacted] ពិសិដ្ឋ និងជនជាប់ចោទ

ឈ្មោះ [redacted] លីណា ពិតជាមានចេតនាក្នុងការបង្កឱ្យមានបទល្មើសកើតឡើង ដែលពិតជាបានប៉ះពាល់ដល់ទ្រព្យសម្បត្តិអ្នកដទៃ សន្តិសុខ សុវត្ថិភាព និងសណ្តាប់ធ្នាប់សាធារណៈ ដែលត្រូវជានាការពារដោយច្បាប់ជាធរមាន ។ ម្យ៉ាងវិញទៀត ជនជាប់ចោទទាំងនេះមានស្មារតីល្អ អាចយល់ដឹងនូវអំពើនិងបច្ច័យនៃអំពើរបស់ពួកខ្លួន និងអាចទទួលខុសត្រូវនូវការប្រព្រឹត្តរបស់ពួកខ្លួនបាន ។

៨/- សំអាងហេតុនិងមូលហេតុដែលជាមូលដ្ឋាននៃការប្តឹងចោទប្រកាន់ និងការបញ្ជូនមកជំនុំជម្រះក្នុងដីកាសន្និដ្ឋានស្ថាពរលេខ ៨៤៨ អយយ/២២ ចុះថ្ងៃទី១៥ ខែធ្នូ ឆ្នាំ២០២២ របស់អយ្យការអមសាលាដំបូងខេត្តសៀមរាប និងដីកាសម្រេចបញ្ជូនសំណុំរឿងទៅជំនុំជម្រះលេខ ៥៣២៧ ពស.ព្រស/គ ចុះថ្ងៃទី១៥ ខែធ្នូ ឆ្នាំ២០២២ របស់ចៅក្រមស៊ើបសួរនៃសាលាដំបូងខេត្តសៀមរាប លើជនជាប់ចោទឈ្មោះ [redacted] វាសនា ជនជាប់ចោទឈ្មោះ [redacted] ពិសិដ្ឋ និងជនជាប់ចោទឈ្មោះ [redacted] លីណា មានភាពត្រឹមត្រូវគ្រប់គ្រាន់តាមមូលដ្ឋានអង្គហេតុ ភស្តុតាង និងនីតិវិធី ដែលគប្បីតុលាការពិនិត្យ ពិចារណា និងសម្រេច តាមភស្តុតាងជាក់ស្តែង ។

៩/- សេចក្តីសន្និដ្ឋានរបស់តំណាងអយ្យការ តាមការស្តាប់ចម្លើយរបស់ជនជាប់ចោទទាំង៣នាក់មានអង្គហេតុនៃការចោទប្រកាន់ពិតប្រាកដមែន ដូច្នេះស្នើសុំតុលាការផ្តន្ទាទោសជនជាប់ចោទតាមច្បាប់ដែលគប្បីតុលាការលើកមកពិចារណា ។

១០/- សេចក្តីសន្និដ្ឋានរបស់មេធាវីការពារសិទ្ធិជនជាប់ចោទ ស្នើសុំតុលាការឱ្យកូនក្តីខ្លួនឈ្មោះ [redacted] វាសនា រួចផុតពីបទចោទ ដែលគប្បីតុលាការពុំលើកមកពិចារណានោះទេ ដោយហេតុថា តុលាការបានរកឃើញថា មានភស្តុតាងបញ្ជាក់ថា ជនជាប់ចោទបានប្រព្រឹត្តដូចការចោទប្រកាន់ ហើយការឆ្លើយសុំនោះពុំមានមូលដ្ឋានច្បាស់លាស់ និងមូលហេតុសមស្របនោះទេ ។

១១/- ផ្អែកតាមអង្គហេតុ ភស្តុតាងនានាដែលជាក់បន្ទុកនិងចម្លើយរបស់ជនជាប់ទាក់ទិននាពេលសវនាការខាងលើ ឃើញថាអំពើប្រព្រឹត្តរបស់ជនជាប់ចោទរបស់ឈ្មោះ [redacted] វាសនា ឈ្មោះ [redacted] ពិសិដ្ឋ បានបំពេញជាតុផ្សំគ្រប់គ្រាន់ និងមានភស្តុតាងលើសពីវិមតិសង្ស័យ បង្ហាញថាជនជាប់ចោទឈ្មោះ [redacted] វាសនា ភេទប្រុស អាយុ១៧ឆ្នាំ (កើតថ្ងៃទី២៩ ខែឧសភា ឆ្នាំ២០០៥) ជនជាតិខ្មែរ សញ្ជាតិខ្មែរ និងឈ្មោះ [redacted] ពិសិដ្ឋ ភេទប្រុស អាយុ២៩ឆ្នាំ (កើតថ្ងៃទី២០ ខែកញ្ញា ឆ្នាំ១៩៩៣) ជនជាតិខ្មែរ សញ្ជាតិខ្មែរ មានពិរុទ្ធភាពពីបទ លួច ប្រព្រឹត្តនៅភូមិសាលាកន្សែង សង្កាត់ស្វាយដង្គំ ក្រុងសៀមរាប ខេត្តសៀមរាប កាលពីថ្ងៃទី១៣ ខែមេសា ឆ្នាំ២០២២ បទល្មើសព្រហ្មទណ្ឌដែលមានចែងឱ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ៣៥៣ និងមាត្រា ៣៥៦ នៃក្រមព្រហ្មទណ្ឌ ។ ចំពោះអំពើប្រព្រឹត្តរបស់ជនជាប់ចោទរបស់ឈ្មោះ [redacted] លីណា បានបំពេញជាតុផ្សំគ្រប់គ្រាន់ និងមានភស្តុតាងលើសពីវិមតិសង្ស័យ បង្ហាញថាជនជាប់ចោទឈ្មោះ [redacted] លីណា ភេទស្រី អាយុ៣៥ឆ្នាំ (កើតថ្ងៃទី១១ ខែកញ្ញា ឆ្នាំ១៩៨៨) ជនជាតិខ្មែរ សញ្ជាតិខ្មែរ មានពិរុទ្ធភាពពីបទសមគំនិតក្នុងអំពើលួច ប្រព្រឹត្តនៅភូមិសាលាកន្សែង សង្កាត់ស្វាយដង្គំ ក្រុងសៀមរាប ខេត្តសៀមរាប កាលពីថ្ងៃទី១៣ ខែមេសា ឆ្នាំ២០២២ បទល្មើសព្រហ្មទណ្ឌដែលមានចែងឱ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ២៩ មាត្រា៣៥៣ និងមាត្រា ៣៥៦ នៃក្រមព្រហ្មទណ្ឌ ។

១២/- ជនជាប់ចោទ មានប្រវត្តិនៃការផ្តន្ទាទោសដោយតុលាការពីមុន និងបានកំពុងអនុវត្តទោសពន្ធនាគារ នៅបន្តប្រព្រឹត្តបទល្មើស ម៉ូតូដែលបានដកហូតពីទីតាំងដែលជនជាប់ចោទឈ្មោះ [redacted] វាសនា ឈ្មោះ [redacted] ពិសិដ្ឋ និងឈ្មោះ [redacted] លីណា បានធ្វើសកម្មភាពល្មើសច្បាប់ លួចយកម៉ូតូរបស់អ្នកដទៃ ។ តាម

បុគ្គលិកលក្ខណៈនៃជនជាប់ចោទ បានប្រព្រឹត្តបទល្មើស មិនឆ្លើយសារភាព ទម្លាក់កំហុសទៅលើអ្នកដទៃ ដែលជាបក្ខពួករបស់ខ្លួន មិនទទួលស្គាល់កំហុស មិនសហការជាមួយអាជ្ញាធរនិងតុលាការមានសមត្ថកិច្ច ព្រមទាំងបង្កឲ្យមានភាពស្មុគស្មាញដល់អង្គសវនាការ ស្ថានភាពនៃបទល្មើស និងទំហំនៃព្យសនកម្ម ដែលតុលាការគប្បីពិនិត្យ ពិចារណា និងសម្រេចផ្តន្ទាទោសលើជនជាប់ចោទឈ្មោះ [redacted] វាសនា ដោយប្រកាសទោសដាក់ពន្ធនាគារ ១ (មួយ) ឆ្នាំ និងឈ្មោះ [redacted] ពិសិដ្ឋ ដោយប្រកាសទោសដាក់ពន្ធនាគារ ២ (ពីរ) ឆ្នាំ ដែលជាទោសតាមច្បាប់ ពីបទ លួច តាមបញ្ញត្តិមាត្រា ៣៥៣ និងមាត្រា ៣៥៦ នៃក្រមព្រហ្មទណ្ឌ និងជនជាប់ចោទឈ្មោះ [redacted] លីណា ដោយប្រកាសទោសដាក់ពន្ធនាគារ ២ (មួយ) ឆ្នាំ ដែលជាទោសតាមច្បាប់ ពីបទ **សមគំនិតក្នុងអំពើលួច** តាមបញ្ញត្តិមាត្រា ២៩ មាត្រា ៣៥៣ និងមាត្រា ៣៥៦ នៃក្រមព្រហ្មទណ្ឌ ។

## ហេតុដូច្នេះសម្រេច

១/- ផ្តន្ទាទោសជនជាប់ចោទឈ្មោះ [redacted] **វាសនា** ភេទប្រុស អាយុ១៧ឆ្នាំ (កើតថ្ងៃទី២៩ ខែឧសភា ឆ្នាំ២០០៥) ជនជាតិខ្មែរ (មានអត្តសញ្ញាណដូចខាងលើ) ដាក់ពន្ធនាគារកំណត់ **១(មួយ)ឆ្នាំ** ។

២/- ផ្តន្ទាទោសជនជាប់ចោទឈ្មោះ [redacted] **ពិសិដ្ឋ** ភេទប្រុស អាយុ២៩ឆ្នាំ (កើតថ្ងៃទី២០ ខែកញ្ញា ឆ្នាំ១៩៩៣) ជនជាតិខ្មែរ (មានអត្តសញ្ញាណដូចខាងលើ) ដាក់ពន្ធនាគារកំណត់ **២(ពីរ)ឆ្នាំ** ។

ពីបទ **លួច** ប្រព្រឹត្តនៅចំណុចភូមិសាលាកន្សែង សង្កាត់ស្វាយដង្គំ ក្រុងសៀមរាប ខេត្តសៀមរាប កាលពីថ្ងៃទី១៣ ខែមេសា ឆ្នាំ២០២២ បទល្មើសព្រហ្មទណ្ឌដែលមានចែងឱ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ៣៥៣ និងមាត្រា ៣៥៦ នៃក្រមព្រហ្មទណ្ឌ ។

៣/- ផ្តន្ទាទោសជនជាប់ចោទឈ្មោះ [redacted] **លីណា** ភេទស្រី អាយុ៣៥ឆ្នាំ (កើតថ្ងៃទី១១ ខែកញ្ញា ឆ្នាំ១៩៨៨) ជនជាតិខ្មែរ (មានអត្តសញ្ញាណដូចខាងលើ) ដាក់ពន្ធនាគារកំណត់ **២(ពីរ)ឆ្នាំ** ។

ពីបទ **សមគំនិតក្នុងអំពើលួច** ប្រព្រឹត្តនៅចំណុចភូមិសាលាកន្សែង សង្កាត់ស្វាយដង្គំ ក្រុងសៀមរាប ខេត្តសៀមរាប កាលពីថ្ងៃទី១៣ ខែមេសា ឆ្នាំ២០២២ បទល្មើសព្រហ្មទណ្ឌដែលមានចែងឱ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា២៩ មាត្រា ៣៥៣ និងមាត្រា ៣៥៦ នៃក្រមព្រហ្មទណ្ឌ ។

សាលក្រមនេះ ជំនុំជម្រះជាអសាធារណៈ នៅថ្ងៃទី២២ ខែកុម្ភៈ ឆ្នាំ២០២៣ ចំពោះមុខជនជាប់ចោទ និងកំបាំងមុខដើមបណ្តឹងរដ្ឋប្បវេណី និងប្រកាសជាសាធារណៈ នៅថ្ងៃទី៩ ខែមីនា ឆ្នាំ២០២៣ ។

បើកសិទ្ធិប្តឹងទាស់ និងប្តឹងឧទ្ធរណ៍តាមកំណត់ច្បាប់ ។

| **ក្រឡាបញ្ជីសវនាការ** | **ចៅក្រមប្រឹក្សា** | **ប្រធានក្រុមប្រឹក្សាជំនុំជម្រះ** |
|---|---|---|
| ហត្ថលេខា និង ត្រា | ហត្ថលេខា និង ត្រា | ហត្ថលេខា និង ត្រា |

[redacted]

**"បានចម្លងត្រឹមត្រូវតាមច្បាប់ដើម"**

ថ្ងៃព្រហស្បតិ៍ ៣រោច ខែផល្គុន ឆ្នាំខាល ចត្វាស័ក ព.ស ២៥៦៦

ខេត្តសៀមរាប ថ្ងៃទី៩ ខែមីនា ឆ្នាំ២០២៣

**ក្រឡាបញ្ជី**

[redacted]

បានឃើញ

**ប្រធានក្រុមប្រឹក្សាជំនុំជម្រះ**

[redacted]



Scanned with CamScanner